**សេចក្តីប្រកាសព័ត៌មាន**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩**

# ពិធីសម្ពោធគម្រោងកែលំអក្រុមហ៊ុនផ្គត់ផ្គង់ទឹកកម្ពុជា~អូស្ត្រាលី

កាលពីសប្តាហ៍មុន ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា បានបើកសម្ពោធគម្រោងកែលំអក្រុមហ៊ុនផ្គត់ផ្គង់ទឹកកម្ពុជា~អូស្ត្រាលី (WUIP) ។ គម្រោងនេះ នឹងគាំទ្រដល់ក្រុមហ៊ុនផ្គត់ផ្គង់ទឹកកម្ពុជាទូទាំងប្រទេសកម្ពុជាឲ្យផ្តល់សេវាផ្គត់ផ្គង់ទឹកកាន់តែប្រសើរឡើង។

គម្រោង WUIP នឹងផ្សារភ្ជាប់ក្រុមហ៊ុន South East Water ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ទឹកធំមួយស្ថិតនៅក្រុង Melbourne ប្រទេសអូស្ត្រាលី ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ទឹកឯកជនកម្ពុជាចំនួនបី តាមរយៈកម្មវិធីចែករំលែកចំណេះដឹងដែលមានរយៈពេលពីរឆ្នាំ ដើម្បីធ្វើអោយការប្រើប្រាស់ទឹក ប្រកបដោយសុវត្ថិភាព និងទៀងទាត់កាន់តែប្រសើរឡើង សម្រាប់ពលរដ្ឋកម្ពុជារាប់ពាន់នាក់។ ភាពជាដៃគូនេះ នឹងផ្តល់បច្ចេកទេសខ្ពស់ និងបទពិសោធន៍គ្រប់គ្រងរបស់ក្រុមហ៊ុនទឹកអូស្ត្រាលី ដល់ក្រុមហ៊ុនផ្គត់ផ្គង់ទឹកកម្ពុជា។

គម្រោងនេះ ជាផ្នែកមួយនៃកម្មវិធីវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរបស់អូស្ត្រាលី ហៅកាត់ថា 3i ដែលកំពុងផ្តល់បណ្តាញទឹកស្អាតដល់ពលរដ្ឋកម្ពុជារាប់លាននាក់។

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោកជំទាវ Angela Corcoran មានប្រសាសន៍ថា៖ «កម្មវិធីនេះនឹងបង្កើតទំនាក់ទំនងយូរអង្វែង ព្រមទាំងផ្លាស់ប្តូរចំណេះដឹងរវាងស្ថាប័នកម្ពុជា និងអូស្ត្រាលី។ នេះជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់អូស្ត្រាលី ដើម្បីជួយកម្ពុជាក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មប្រកបដោយគុណភាព ដើម្បីអោយកម្ពុជាក្លាយទៅជាប្រទេសមួយរីកចម្រើន រឹងមាំ និងប្រកបដោយបរិយាបន្ន»។

គម្រោង WUIPនេះ កំពុងត្រូវបានសម្របសម្រួលដោយសមាគមន៍ទឹកអូស្ត្រាលី (AWA) ជាមួយដៃគូគឺសមាគមន៍ផ្គត់ផ្គង់ទឹកកម្ពុជា (CWA)។

លោក Jonathan McKeown នាយកប្រតិបត្តិសមាគមន៍ទឹកអូស្ត្រាលីមានប្រសាសន៍ថា៖ «តាមរយៈដៃគូរបស់យើង វិស័យទឹកកម្ពុជា~អូស្ត្រាលី នឹងធ្វើការរួមគ្នាក្នុងការផ្តល់ដំណោះស្រាយទឹកដោយចែករំលែកនូវជំនាញនិងបច្ចេកទេសថ្មីៗ»។

លោក ហោ ឃីកេង នាយកប្រតិបត្តិសមាគមន៍ទឹកកម្ពុជាមានប្រសាសន៍ថា៖ «តំណាងអោយក្រុមហ៊ុនផ្គត់ផ្គង់ទឹកមួយនៅកម្ពុជា សមាគមន៍ទឹកកម្ពុជា និងសមាជិក មានមោទនភាពក្នុងការធ្វើជាដៃគូជាមួយសមាគមន៍ទឹកអូស្ត្រាលី និងក្រុមហ៊ុនផ្គត់ផ្គង់ទឹក South East Water ហើយមានសេចក្តីរំភើបដែលបានធ្វើការជាមួយវិស័យទឹកអូស្ត្រាលីដើម្បីកែលំអការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកទូទាំងប្រទេសកម្ពុជាតាមរយៈការផ្លាស់ប្តូរចំណេះដឹង ជំនាញ និងបច្ចេកវិទ្យាថ្មីៗ»។

គំរោងWUIP ពាក់ព័ន្ធជាមួយការផ្លាស់ប្តូរបុគ្គលិកគ្នាទៅវិញទៅមករវាងក្រុមហ៊ុនផ្គត់ផ្គង់ទឹកអូស្ត្រាលី South East Water និងក្រុមហ៊ុនផ្គត់ផ្គង់ទឹកកម្ពុជាដើម្បីធ្វើឲ្យការគ្រប់គ្រងឧបករណ៍ផលិតទឹក ទំនាក់ទំនងអតិថិជន ការកែលំអគុណភាពទឹក និងបច្ចេកវិទ្យាថ្មីៗកាន់តែប្រសើរឡើង។

លោក Terry Schubach អ្នកចាត់ការទូទៅផ្នែកផ្តល់សេវាកម្មអតិថិជននៃក្រុមហ៊ុន South East Water មានប្រសាសន៍ថា៖ «ក្រុមហ៊ុនផ្គត់ផ្គង់ទឹកអូស្ត្រាលី South East Water មានសេចក្តីសោមនស្សរីករាយដែលបានធ្វើការរួមគ្នាក្នុងគំរោង WUIP នេះ។ យើងនឹងរង់ចាំចែករំលែកចំណេះដឹងរបស់យើងក្នុងការគាំទ្រវិស័យផ្គត់ផ្គង់ទឹកនៅកម្ពុជាដើម្បីធ្វើអោយសេវាផ្គត់ផ្គង់ទឹកបានប្រសើរឡើង។ យើងសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលអូស្ត្រាលី ក៏ដូចសមាគមន៍ទឹកអូស្ត្រាលីដែលបានគាំទ្រក្នុងការផ្តល់ឱកាសដ៏រំភើបនេះ»។

ដោយបន្តការងារនេះ សមាគមន៍ទឹកអូស្ត្រាលី និងសមាគមន៍ទឹកកម្ពុជា នឹងអញ្ជើញប្រតិភូអូស្ត្រាលីមួយក្រុមដើម្បីចូលរួមសន្និសិទតាំងពិពណ៌ទឹកនៅកម្ពុជាប្រព្រឹត្តិទៅនាខែតុលាខាងមុខនេះ ដែលសន្និសិទនេះនឹងបង្កើតឱកាសបន្ថែមទៀតសម្រាប់ការសហការ និងផ្លាស់ប្តូរចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗទៅវិញទៅមក។

ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ Australian.Embassy.Cambodia@dfat.gov.au